ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៦ លេខ ១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក
ស
វ



# Work Activities

ប្រចាំខែមករា ឆ្នាំ២០១៣



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកំសាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ | ១ |
| ២- | សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៣-២០១៥ | ៣ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែវិច្ឆិកា ឆ្នាំ២០១២ | ៥ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១២ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការគ្រប់គ្រងមណ្ឌលកំសាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ

កាលពីថ្ងៃទី៥ ខែតុលា និងថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកំសាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងទេសចរណ៍។



ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា វិស័យទេសចរណ៍កម្ពុជាមានការរីកចម្រើនជាលំដាប់។ ជាក់ស្តែង ក្នុងឆ្នាំ២០១១កន្លងមកនេះ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិចំនួន ២ ៨៨១ ៨៦២ នាក់ កើនឡើងប្រមាណ ១៤,៩% ដែលផ្តល់ឱកាសការងារជាច្រើនជូនប្រជាពលរដ្ឋ និងនាំមកនូវចំណូលប្រមាណ ១ ៩១២ លានដុល្លារ ដែលរួមចំណែកប្រមាណ ១២% នៃ GDP។ ក្នុងឆ្នាំ២០១៥ ភ្ញៀវទេសចរអន្តរជាតិនឹងអាចកើនឡើងប្រមាណចំនួន ៤,៥ លាននាក់ ដែលនឹងអាចផ្តល់ចំណូលទេសចរណ៍ ក្នុងរង្វង់ ២ ៥០០ លានដុល្លារ។ ទិន្នន័យនេះមិនទាន់គិតបញ្ចូលសកម្មទេសចរណ៍ក្នុងស្រុកដែលមានប្រមាណ ៦ លាននាក់ ក្នុងមួយឆ្នាំ ដែលផ្តល់ចំណូលប្រមាណ ១០០ លានដុល្លារ ថែមទៀតក្នុងចរន្តសេដ្ឋកិច្ចកម្ពុជា។

ការកើនឡើងនូវភ្ញៀវទេសចរអន្តរជាតិ ក៏ដូចជាកំណើនទេសចរក្នុងស្រុក យើងសង្កេតឃើញថា មូលដ្ឋានអាជីវកម្មទេសចរណ៍គ្រប់ប្រភេទក៏មានសន្ទុះកើនឡើងគួរឲ្យកត់សម្គាល់ ជាពិសេសមូលដ្ឋានអាជីវកម្មសេវាកម្ម កម្សាន្តទេសចរណ៍មនុស្សពេញវ័យ។ ការកើនឡើងនេះគឺជាការឆ្លើយតបភ្លាមៗទៅនឹងតម្រូវការរបស់ភ្ញៀវទេសចរ។ មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យសំដៅដល់ទីតាំងសេវាកម្មទាំងឡាយដែល

ធ្វើអាជីវកម្ម ដើម្បីបម្រើឲ្យការសម្រាក លម្ហែ និងកម្សាន្តសម្រាប់មនុស្សពេញវ័យ ដូចជាអាជីវកម្មរង្គសាល អាជីវកម្មឌីស្កូតែក អាជីវកម្មខារ៉ាអូខេ និងអាជីវកម្មបៀហ្គាឌិន។

មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ គឺជាកន្លែងសម្រាកលំហែដ៏សំខាន់នៅក្នុងវិស័យទេចរណ៍ និងជាកន្លែងដែលទាក់ទាញភ្ញៀវទេចរផងដែរ។ ប្រសិនបើគ្មានការគ្រប់គ្រងឲ្យបានល្អ វានឹងបង្កឲ្យមានផលប៉ះពាល់ដល់សុវត្ថិភាព សណ្តាប់ធ្នាប់ វប្បធម៌ និងប្រពៃណីជាតិ។ ជាក់ស្តែងមុនពេលពុំទាន់មានច្បាប់ស្តីពីទេសចរណ៍ ក្រសួងទេសចរណ៍បានរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដូចជាប្រកាសនិងសារាចរណ៍ណែនាំ ដើម្បីធ្វើការគ្រប់គ្រងអាជីវកម្មសេវាកម្សាន្តទេសចរណ៍។ បន្ទាប់ពីច្បាប់ស្តីពីទេសចរណ៍ត្រូវបានអនុម័តដាក់ឲ្យប្រើប្រាស់ ក្រសួងបានសហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើការអប់រំណែនាំឲ្យដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ និងធ្វើការផ្អាកអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មួយចំនួនដែលគ្មានច្បាប់អនុញ្ញាត។ លើសពីនេះក្រសួងបាន ចេញសារាចរណ៍ណែនាំដល់ម្ចាស់អាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍ទាំងអស់ឲ្យចូលរួមអនុវត្តច្បាប់ស្តីពីទេសចរណ៍ ដូចជាការហាមឃាត់អនីតិជនមិនឲ្យចូលកំសាន្ត ជាពិសេសចូលរួមអនុវត្តឲ្យបានម៉ឺងម៉ាត់នូវសារាចរ ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីវិធានការទប់ស្កាត់និងបង្ក្រាប "ក្មេងទំនើង"។




អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីពាងអនុក្រឹត្យនេះ ហើយបានសម្រេចកែសម្រួល ទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១)
អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកំសាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ។

# សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០១៣-២០១៥

កាលពីថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **តាំង គុនហ៊ាង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC)និង ឯកឧត្តម **សុក ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៣-២០១៥ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី [illegible] [illegible] មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងផែនការ។



ក្រសួងផែនការបានរៀបចំសេចក្តីព្រាងឯកសារកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល២០១៣-២០១៥ ដោយផ្អែកលើស្មារតីនិងខ្លឹមសារនៃ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ។ កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៣-២០១៥(ក.វ.ស.) លើកនេះ ត្រូវបានរៀបចំឡើងដោយមានការគិតគូរដល់កត្តាចម្បង និងស្ថានភាពជាក់ស្តែងបីសំខាន់ៗ ពោលគឺ ទី១-ការបង្ហាញពីទិន្នន័យគម្រោងវិនិយោគ ដែលមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលជាគោលនយោបាយបាយមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងនៅក្នុង ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ទី២-តម្រូវការចំណាយសរុបសម្រាប់ការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ (ប្រមាណជិត ៦ ៣០០ លានដុល្លារអាមេរិក) និង ទី៣-បរិមាណហិរញ្ញប្បទានសហប្រតិបត្តិការដែលបានសន្យានៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា(វ.ស.អ.ក.)កន្លងមក (ប្រមាណជិតមួយពាន់លានដុល្លារ) និងការទទួលបានហិរញ្ញប្បទានសម្រាប់អនុវត្តជាក់ស្តែងកន្លងទៅនេះ។

ក.វ.ស. បីឆ្នាំរំកិល ២០១៣-២០១៥ ដែលមានតម្លៃសរុបប្រចាំឆ្នាំ ប្រមាណ ១ ២៥០ លានដុល្លារអាមេរិក ត្រូវបានរៀបចំឡើង ដោយផ្អែកលើតម្រូវការចំណាយសរុបសម្រាប់ការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម

២០០៩-២០១៣ (៦ ៣០០ លានដុល្លារអាមេរិក) ដើម្បីឲ្យស្របតាមស្ថានភាពជាក់ស្តែងនៃការប្រែប្រួលថ្លៃទំនិញ និងអតិផរណា ហើយក៏ផ្អែកលើបរិមាណហិរញ្ញប្បទានសហប្រតិបត្តិការដែលដៃគូអភិវឌ្ឍន៍ធ្លាប់បានសន្យានៅក្នុង វ.ស.អ.ក. កន្លងទៅនេះ (ប្រមាណជិតមួយពាន់លានដុល្លារ) ផងដែរ។

ក.វ.ស. បីឆ្នាំរំកិល ២០១៣-២០១៥ មានគម្រោងសរុបចំនួន៤២១ ក្នុងនោះមាន ១៧៩ គម្រោង កំពុងដំណើរការ ដែលត្រូវការទុនចំនួន ២ ៥៩៥លានដុល្លារអាមេរិក និង ២៤២គម្រោងជាគម្រោងសម្រាប់អនុវត្តផយអជ ត្រូវការទុនចំនួន ១ ៧៦៧ លានដុល្លារអាមេរិក។ ជាសរុប សម្រាប់ ក.វ.ស. បីឆ្នាំរំកិល ២០១៣-២០១៥ នេះត្រូវការទុនចំនួន ៤ ៣៦២ លានដុល្លារអាមេរិក រួមមានៈ សម្រាប់ឆ្នាំ២០១៣ ត្រូវការចំនួន ១ ៥៤៦ លានដុល្លារអាមេរិក ឆ្នាំ២០១៤ ត្រូវការចំនួន ១ ៣៩៧ លានដុល្លារអាមេរិក និងឆ្នាំ២០១៥ ត្រូវការចំនួន ១ ៤១៩ លានដុល្លារអាមេរិក។ បរិមាណទុនសរុប ៤ ៣៦២ លានដុល្លារអាមេរិក នៃ ក.វ.ស. បីឆ្នាំរំកិល ២០១៣-២០១៥ ក្នុងនោះបរិមាណទុនដែលបានសន្យាផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍រួចហើយមានចំនួន ៣ ០៥២ លានដុល្លារអាមេរិក(ក្នុងនោះពីរាជរដ្ឋាភិបាលកម្ពុជាចំនួន ៥៤៦ លានដុល្លារអាមេរិក និងពីដៃគូអភិវឌ្ឍន៍ចំនួន ២ ៥០៥ លានដុល្លារអាមេរិក) ដោយត្រូវការទុនបន្ថែមចំនួន ១ ៣០៩ លានដុល្លារអាមេរិក(១)។




អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៣-២០១៥។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣ ដែលដឹកនាំដោយឯកឧត្តម **យឹម ឆៃលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែវិច្ឆិកា ឆ្នាំ២០១២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថយចុះ ០,២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន(រយៈពេល១២ខែ)។ ការចុះថ្លៃទំនិញប្រើប្រាស់ធៀបនឹងខែមុននេះ ជាចម្បងបណ្តាលមកពីក្រុមម្ហូបអាហារមានការចុះថ្លៃ។

| បើធៀបនឹងខែដូចគ្នាឆ្នាំមុន ក្រុមទំនិញនិងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម | | |
|---|---|---|
| ***ក្រុមទំនិញ:*** | ***មុខទំនិញ:*** | |
| ម្ហូបអាហារ : +១,២% | អង្ករ : +២,០% | ឧស្ម័ន: +៣,៧% |
| សម្លៀកបំពាក់ និងស្បែកជើង : +៣,១% | សាច់ជ្រូក : -១០% | ប្រេងសាំង: +៤,៩% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន : +២,៥% | សាច់គោស្រស់: +១៥% | ប្រេងម៉ាស៊ូត: +៥,៧%។ |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ : +៣,២% | ត្រីស្រស់ : +១,៦% | |
| ការដឹកជញ្ជូន: +១,៦% | បន្លែ: +៥,២% | |
| ភោជនីយដ្ឋាន: +៤,៤% | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំង៥ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១០–២០១២

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ^P | ប្រចាំឆ្នាំ^P |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ១,៤% | ២,៨% |
| | ខែមុន | ១,០ | ០,៤ | ០,៦% | ០,៥% | -១,១% | ០,១% | ០ | ១,១% | ០,២% | -០,២% | -០,២% | -១,១% | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៧% | -០,៨% | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | ០% | ០,៣% | ០,៦% | -០,៣% | ០,២% | ០% | ០,៥% | ០,៩% | ០,៧% | ១,៤% | –១,០% | –០,២% | |

P: តួលេខខែធ្នូនិងប្រចាំឆ្នាំ២០១២ ជាតួលេខព្យាករដោយក.ស.វ. (តាមវិធីសាស្ត្រ DECOMPOSITION)

ក្រាហ្វ ១. បម្រែបម្រួលថ្លៃទំនិញប្រើប្រាស់ ឆ្នាំ ២០១១ និង២០១២ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)។

ក្រាហ្វបង្ហាញនិន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃ (ធៀបនឹងខែដូចគ្នាឆ្នាំមុន) សម្រាប់ឆ្នាំ ២០១១ និង ២០១២ និងអត្រាអតិផរណានាខែធ្នូ ឆ្នាំ២០១២។




**➡អត្រាប្តូរប្រាក់៖**

| *ប្រភេទ* | អត្រាខែវិច្ឆិកា ២០១២ | អត្រាខែតុលា ២០១២ | អត្រាខែវិច្ឆិកា ២០១១ | *ប្រភេទ* | អត្រាខែវិច្ឆិកា ២០១២ | អត្រាខែតុលា ២០១២ | អត្រាខែវិច្ឆិកា ២០១១ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៣៩៩២៛/១$ | ៤០៣០៛/១$ | ៤០៣១៛/១$ | **បាត/ដុល្លារ** | ៣០,៦៨បាត/១$ | ៣០,៧១បាត/១$ | ៣១,២៥បាត/១$ |
| **៛/បាត** | ១៣០៛/១បាត | ១៣១៛/១បាត | ១២៩៛/១បាត | **ដុង/ដុល្លារ** | ២០៨៤០ដុង/១$ | ២០៨៣០ដុង/១$ | ២១០០៩ដុង/១$ |
| **៛/ដុង** | ០,១៩១៛/១ដុង | ០,១៩៣៛/១ដុង | ០,១៩២៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

- *ចំណូលថវិកាជាតិអនុវត្តបានចំនួន ៥៣០,១ ពាន់លានរៀល (មធ្យមប្រចាំខែ ៧០% នៃគម្រោង) ក្នុងនោះ:* ចំណូលចរន្តចំនួន ៥៣០,១ ពាន់លានរៀល (មធ្យមប្រចាំខែ ៩៨% នៃគម្រោង) និងមិនមានចំណូលមូលធនទេក្នុងខែវិច្ឆិកានេះ។
- បើធៀបនឹងខែមុន**ចំណូលថវិកាជាតិ**ថយចុះ ៩% និងថយចុះ ៤% *ធៀបនឹងខែដូចគ្នាឆ្នាំមុន* ។ ការថយចុះធៀបនឹងខែដូចគ្នាឆ្នាំមុន បណ្តាលមកពីចំណូលចរន្តថយចុះ ៣% និងអវត្តមានចំណូលមូលធន។
- នៅក្នុងចំណូលចរន្ត៖

**ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១១ និង ២០១២**
(ពាន់លានរៀល)



- ✓ ចំណូលសារពើពន្ធមានចំនួន ៤៧៥,២ ពាន់លានរៀល កើនឡើង ០,២% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។
- ✓ ចំណូលមិនមែនសារពើពន្ធមានចំនួន ៥៤,៩ ពាន់លានរៀល ថយចុះ ៣៩% ធៀបនឹងខែមុន និងថយចុះ ១០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | មុខចំណូលមួយចំនួនក្នុងចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ : +៤% | (+១៨% ) | ➢ នេសាទ: +៥៧% | (-៧៦%) |
| ➢ ចំណូលពន្ធដារ : -៩% | (+៨%) | ➢ រុក្ខាប្រមាញ់ : -៥០% | (-២%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: +៨% | (+៣៣%) | ➢ អាកាសចរណ៍ស៊ីវិល : -៥៤% | (-៣១%) |
| ✧ កាស៊ីណូ : +១៥% | (+៦៣%) | ➢ ផលទុនទេសចរណ៍ : -៥០% | (-២៧%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +៩១% | (+១១៥%) | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : -៩% | (-២៣%) |
| ✧ កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : +២% | (+១១៧%) | ➢ អាករស្ថានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ): +១៣% | (-១%) |

↳ ***ចំណាយថវិកាជាតិ*** អនុវត្តបានចំនួន ៤៨៥ ពាន់លានរៀល (*មធ្យមប្រចាំខែ ៥៩% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៤០៤ ពាន់លានរៀល (*មធ្យមប្រចាំខែ ៨៧% នៃគម្រោង*) និង**ចំណាយមូលធន**ចំនួន ៨១ ពាន់លានរៀល។

↳ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** កើនឡើង ៦% ប៉ុន្តែថយចុះ ២៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្តកើនឡើង ៩% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៣៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯ**ចំណាយមូលធន** ថយចុះ ៧% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៥២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

↳ *ថវិកាជាតិនៃខែវិច្ឆិកាមាន**អតិរេក ៤៥** ពាន់លានរៀល ស្មើនឹង ១១,២ លានដុល្លារ ស.រ.អា ។*

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ មានលក្ខណៈដូចខាងក្រោម៖

↳ រូបិយវត្ថុ $M_2$ មានចំនួន ២៧៦៤៣ ពាន់លានរៀល កើនឡើង ០,៧% ធៀបនឹងខែមុន និងកើនឡើង ២១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

↳កំណើនរូបិយវត្ថុ $M_2$ ធៀបនឹងខែមុន បណ្តាលមកពីរូបិយវត្ថុក្រៅធនាគារកើនឡើង ០,៣% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំកើនឡើង ៣% និងប្រាក់បញ្ញើជារូបិយបណ្ណ កើនឡើង ០,៧%។

↳ ក្នុងខែនេះ ប្រាក់រៀលសរុប**នៅក្នុងនិងក្រៅធនាគារ** មានចំនួន ១៧% នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណ មានចំនួន ៨៣%។

**ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុ ខែតុលា ឆ្នាំ២០១២**



| សមាមាត្រចំនួនប្រាក់រៀល ទៅនឹងរូបិយវត្ថុ $M_2$ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៩,២% | ១៨,៣% | ១៩,៦% | ១៩,៣% | ១៨,៦% | ១៧,៥% | ១៧,៥% | ១៦,៩% | ១៦,៨% | ១៦,៦% | ១៦,៦% | |
| ប្រាក់រៀលក្រៅធនាគារ | ១៥,២% | ១៥,២% | ១៥,៣% | ១៤,៨% | ១៤,៧% | ១៣,៦% | ១៣,៦% | ១៣,៦% | ១៣,៤% | ១៣,១% | ១៣,១% | |

**បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែវិច្ឆិកា២០១២: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន**




- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៣៣៤៦ លានដុល្លារ កើនឡើង ១,៥% ធៀបនឹងខែមុន និងកើនឡើង ១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ***ក្នុងខែនេះមានចំនួន ៩៣២០ ពាន់លានរៀល ស្ថិតនៅថេរ ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** មានចំនួន **២២០៥២ ពាន់លានរៀល** កើនឡើង ១,៦% ធៀបនឹងខែមុន និងកើនឡើង ៣០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** (មិនទាន់មានតួលេខ)
- ***អត្រាការប្រាក់ប្រចាំឆ្នាំ*** នៅធនាគាពាណិជ្ជនាខែវិច្ឆិកា៖

| *ប្រភេទអត្រាការប្រាក់* | *វិច្ឆិកា ២០១២* | *តុលា ២០១២* | *វិច្ឆិកា ២០១១* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៥,៨៦% | ៦,៤៦% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៨១% | ១៩,៣៤% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៤,៤២% | ៤,៤៣% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៩៧% | ១៤,៩៩% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែវិច្ឆិកាឆ្នាំ២០១២ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

- **កសិកម្ម៖**
  - ✓ ផលិតផលនេសាទ(មិនទាន់មានតួលេខ)

### ឧស្សាហកម្ម៖

- ✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២៩១,៤ GWh កើនឡើង ៦% ធៀបនឹងខែមុន និងកើនឡើង ៣២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
  - ⇨ វារីអគ្គិសនីមានចំនួន ២៤,៨ GWh ថយចុះ ៦៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣៦០ លានដុល្លារ កើនឡើង ១២% ធៀបនឹងខែមុន និងកើនឡើង ៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន –វិច្ឆិកា ២០១២ | ចំនួន–តុលា ២០១២ | ចំនួន–វិច្ឆិកា ២០១១ |
|---|---|---|---|
| ▪ រោងចក្រថ្មី | ១៩ | ២៣ | ៥ |
| ▪ ចំនួនរោងចក្រសរុប | ៨៨៩ | ៨៧០ | ៦៩៣ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ៣១ | ៣០ | ១០ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ២៥ | ៤៣ | ១៦ |

### សំណង់ (ការអនុញ្ញាត)៖

- ✓ សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៣៥០ ពាន់ម² កើនឡើង ១០% ធៀបនឹងខែមុន និងថយចុះ ៧៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹងចំនួន ១១៤ លានដុល្លារ កើនឡើង ២៩% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៨១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

| ប្រភេទ | ពាន់ម² –វិច្ឆិកា ២០១២ | ពាន់ម² –តុលា២០១២ | ពាន់ម² –វិច្ឆិកា ២០១១ |
|---|---|---|---|
| ▪ លំនៅឋាន | ៨៤,៧ | ៩៩,៧ | ២៩៧,៨ |
| ▪ ឧស្សាហកម្ម | ៤៨,៨ | ១៦៥,៧ | ៥៥,២ |
| ▪ ពាណិជ្ជកម្ម | ១៦៦,៣ | ១៥,៣ | ៧,៩ |
| … | | | |
| អនុញ្ញាតសរុប | ៣៥០ | ៣១៩ | ១៤៨៧ |

- ✓ សំណង់ដែលពេញនិយមនាខែនេះគឺ ពាណិជ្ជកម្ម (៤៨% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) និងសំណង់លំនៅឋាន (២៤% នៃផ្ទៃក្រឡាអនុញ្ញាតសរុប)។

### ការងារ៖

| ប្រភេទ | នាក់–វិច្ឆិកា២០១២ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១៧៦៤ | +២៤% | +២៧% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៤៤៧៩ | +៧៤% | +៤២% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៣០៨៤ | +១៣២% | +៣៨% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៣៩៥ | +១៣% | +៥២% |

### វិនិយោគ៖

- ✓ គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក) ក្នុងខែវិច្ឆិកាមានចំនួន ៩ គម្រោង ដែលជាទុនវិនិយោគស្មើនឹង ៣៧ លានដុល្លារ។ គម្រោងទាំងនេះអាចបង្កើតការងារបាន ១៥ ពាន់នាក់។

| ប្រភេទ | វិច្ឆិកា២០១២ | តុលា២០១២ | វិច្ឆិកា២០១១ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៥៥ | ៦៩៧ | ៩៧៣ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ៦ | ១៧៥ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៣៧ (១៧) | ៤២ (៩) | ៥០ (០) |
| វិស័យទេសចរណ៍ | ០ | ៦៤១ | ១២ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ៤៦៥ |

| | | | |
|---|---|---|---|
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៦ | ១៧ | ២១ |
| បង្កើតការងារ (ពាន់នាក់) | ១៨ | ២២ | ៣៣ |

### សេវាកម្ម និងទេសចរណ៍៖

✓ **ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន–វិច្ឆិកា២០១២ | ចំនួន– តុលា២០១២ | ចំនួន–វិច្ឆិកា២០១១ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២១៧ | ២២៩ | ២២៦ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៤ | ២ | ១ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ១៧២ | ១៩៧ | ១៩៩ |

✓ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៥កំពង់ផែ) មានចំនួន ៤៧៦ ពាន់តោន កើនឡើង ១១% ធៀបនឹងខែមុន និង កើនឡើង ១៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ: -៤% | (+៥%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: +១% | (-៥៣%) |
| ▪ កំពង់ផែកំពង់សោម: +៤៧% | (+៣៨%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -៣៩% | (+៩០០%) |

### ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖

| ប្រភេទ | ចំនួន (ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៧០ | -១% | +៦% |
| ចំនួនទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ៣៣៣ | +១៥% | +២៦% |
| ✓ តាមផ្លូវអាកាស | ១៦៩ | +២០% | +១៣% |
| ✓ តាមផ្លូវគោក និងទឹក | ១៦៥ | +១០% | +៤២% |

សូចនាករណ៍ "ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ" "អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក)" និង"អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ)" ក្នុងខែនេះមិនទាន់មានតួលេខ។

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលនាខែវិច្ឆិកាមានចំនួន ២៦២២ ពាន់លានរៀល (ស្មើនឹង ៦៥៥ លានដុល្លារ ស.រ.អា.) កើនឡើង ២% ធៀបនឹងខែមុន និងកើនឡើង ១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +៧% | -១% | ម៉ូតូ (គ្រឿង) | +៤៧% | +២៩៤% |
| ប្រេងម៉ាស៊ូត | +១% | +២៧% | ផ្លែឈើ និងបន្លែ | +១% | ០ |
| ឧស្ម័ន | +៤០% | +១៨% | ស៊ីម៉ង់ត៍ | -៨% | +៥២% |
| ដែកសំណង់ | +២៥% | +១៧៣% | គ្រឿងអេឡិចត្រូនិក | -១៣% | -២៨% |
| រថយន្តសរុប (ព.ល.រ) | ០ | +១៥% | អង្ករ | -៨៥% | +៦៦១% |
| រថយន្តសរុប (គ្រឿង) | +៦% | +២១% | ជី និងថ្នាំកសិកម្ម | -១៦% | +១១២% |
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៦% | +៣២២% | ការនាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -៩% | -៣% |

➡ **ការនាំចេញ** ក្នុងខែវិច្ឆិកាឆ្នាំ២០១២ មានចំនួន ២០៦៤ ពាន់លានរៀល ស្មើនឹង ៥១៦លានដុល្លារ ស.រ.អា. (៧៩% នៃការនាំចូល) កើនឡើង ២៣% ធៀបនឹងខែមុន និងកើនឡើង ៣២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %△ ធៀបនឹង ខែមុន | %△ ធៀបនឹងខែ ដូចគ្នាឆ្នាំមុន | ទំនិញ | %△ ធៀបនឹង ខែមុន | %△ ធៀបនឹងខែ ដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៩៨% | -៦៩% | កៅស៊ូ | +៣៩% | +៦៨% |
| វាយនភណ្ឌនិងស្បែកជើង | +១៩% | +១៨% | ផលិតផលនេសាទ | +៩៦% | -២៨% |
| អង្ករ | +២៣% | +៦២% | | | |

➡ ក្នុងខែវិច្ឆិកានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៥៥៨ ពាន់លានរៀល ស្មើនឹង ១៤០ លានដុល្លារ ស.រ.អា.។

### ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែវិច្ឆិកា ឆ្នាំ២០១២នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ធៀបនឹង ខែមុន | ធៀបនឹងខែ ដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណូលថវិកាជាតិ | -៩% | -៤% | នេះជាលើកទី១ក្នុងឆ្នាំ២០១២ ដែលចំណូលថវិកាជាតិប្រចាំខែទាបជាងចំណូលខែដូចគ្នាឆ្នាំមុន។ |
| ២ | ក្រុមហ៊ុនបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | -១៣% | -១៤% | — |
| ៣ | ទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក. | -៩២% | -៩៤% | — |

## ៧. ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

១) បន្លែជាប្រភេទទំនិញទីពីរក្នុងក្រុមម្ហូបអាហារដែលមានការឡើងថ្លៃខ្ពស់បន្ទាប់ពីសាច់គោ។ បើប្រៀបធៀបសន្ទស្សន៍ថ្លៃមធ្យមរយៈពេល១១ខែដូចគ្នា ឆ្នាំ២០១២ និង២០១១ បន្លែបានឡើងថ្លៃ ៩%រីឯសាច់គោបានឡើងថ្លៃ ១៥%។

២) អង្ករលើទីផ្សារពិភពលោកមានការធ្លាក់ថ្លៃ ដែលប៉ះពាល់ចំណូលរបស់កសិករ និងអាចនាំឲ្យមានផលប៉ះពាល់ដល់ការអនុវត្តផែនការនាំចេញអង្ករ ១លានតោន/ឆ្នាំ ក្នុងឆ្នាំ២០១៥។

៣) សូចនាកររូបិយវត្ថុបង្ហាញថា ប្រាក់រៀលក្រៅធនាគារមានចំនួនដូចគ្នាបើធៀបនឹងខែដូចគ្នាឆ្នាំមុន ប៉ុន្តែជាសមាមាត្រធៀបនឹង M2 ប្រាក់រៀលក្រៅធនាគារថយចុះពី ១៦% នៃM2 មកត្រឹមតែ១៣% ប៉ុណ្ណោះ។ នេះបង្ហាញថាគោលនយោបាយរូបិយវត្ថុនៃធនាគារជាតិមានការរិតត្បិតការបញ្ចេញប្រាក់រៀលមកក្រៅធនាគារ ដែលធ្វើឲ្យប្រាក់រៀលមានការឡើងថ្លៃ និងកម្រិតដុល្លារូបនីយកម្មនៃសេដ្ឋកិច្ចកម្ពុជាមានការកើនឡើង ពីព្រោះមានការងាកទៅរកការចាយវាយជាដុល្លារច្រើនជាងការចាយវាយជាប្រាក់រៀល ។

***សេចក្តីសន្និដ្ឋាន៖***

១) ការឡើងថ្លៃនៃបន្លែ និងសាច់គោ ជាកត្តានៃតម្រូវការ និងការផ្គត់ផ្គង់។ កម្ពុជាត្រូវបង្កើនការផ្គត់ផ្គង់បន្លែ-សាច់ឲ្យបានគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងតម្រូវការនៃអ្នកប្រើប្រាស់ក្នុងស្រុក និងទេសចរណ៍ **តាមរយៈការជំរុញការផលិតនៅក្នុងស្រុក។**

២) ការធ្លាក់ថ្លៃអង្ករលើទីផ្សារពិភពលោក ដោយសារការប្រឹងប្រែងបង្កើនការផ្គត់ផ្គង់របស់ក្រុមប្រទេសផលិតអង្ករ។ ក្នុងទីផ្សារអង្ករនៅខ្វះការសហការគ្នារវាងប្រទេសអ្នកផលិតក្នុងគោលដៅរក្សាថ្លៃអង្ករឲ្យនៅខ្ពស់ (ខុសពីក្រុមប្រទេសផលិតប្រេងដែលបានបង្កើតអង្គការ OPEC ជាយន្តការសម្រាប់ការគ្រប់គ្រងថ្លៃប្រេងឲ្យនៅខ្ពស់)។

៣) គោលនយោបាយរូបិយវត្ថុរបស់កម្ពុជាគួរតម្រង់ទិសទៅរកបដិដុល្លារូបនីយកម្មជាជំហានៗ។ ដូច្នេះគួរលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឲ្យបានកម្រិតណាមួយរៀងរាល់ឆ្នាំ។ ការណ៍នេះតម្រូវឲ្យធនាគារជាតិរក្សាសមាមាត្រនៃប្រាក់រៀលក្រៅធនាគារ ធៀបនឹងM2 ឲ្យមានការកើនឡើង និងរក្សាស្ថេរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ជាជាងការបណ្តោយឲ្យប្រាក់រៀលឡើងថ្លៃ ឬចុះថ្លៃហួសហេតុពេក។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៣

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | **០២/០១/១៣ ម៉ោង ០៩:០០ នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន។<br>២-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៣-២០១៥។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | **០២/០១/១៣ ម៉ោង ១៦:០០ នាទី** | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន។<br>២-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៣-២០១៥។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | **០៤/០១/១៣ ម៉ោង ០៨:៣០ នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌ឆ្មប។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៤ | **០៥/០១/១៣ ម៉ោង ០៨:០០ នាទី** | ចូលរួមជាសមាជិក ក្នុងសន្និបាតគណបក្សប្រជាជនកម្ពុជាខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តតាកែវ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាខេត្តតាកែវ។ |

# សកម្មភាពផ្សេងៗទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## ប្រចាំខែមករា ឆ្នាំ២០១៣ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៥ | ០៦/០១/១៣<br>ម៉ោង ១៧:០០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីជប់លៀងអបអរសាទរការបញ្ចប់បេសកកម្មជំហានទី១ ក្នុងយុទ្ធនាការវាស់វែងដីធ្លី ដើម្បីផ្តល់កម្មសិទ្ធិជូនប្រជាពលរដ្ឋ របស់ក្រុមវីរៈយុវជនស្ម័គ្រចិត្តសម្តេចតេជោ ក្រុមបច្ចេកទេស ក្រុមគ្រូពេទ្យ ក្រុមដឹកជញ្ជូន និងមន្ត្រីពាក់ព័ន្ធ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលពិព័រណ៍ពាណិជ្ជកម្មកោះពេជ្រ។ |
| ៦ | ០៧/០១/១៣<br>ម៉ោង ០៨:០០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីមិទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៣៤ នៃទិវាជ័យជំនះ ៧មករា និងពិធីចែកបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ក្នុងឃុំអង្គប្រាសាទ ស្រុកគីរីវង់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីធ្លាមុខមន្ទីរគណបក្សខេត្តតាកែវ។ |
| ៧ | ០៨/០១/១៣<br>ម៉ោង ០៨:៣០ នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ០៨/០១/១៣<br>ម៉ោង ១៥:៣០ នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **យឹម ណុលសន** និងលោក **ម៉ក់ ឆារ៉ា** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១៤/០១/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតជ័យលាភីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១០ | ១៤/០១/១៣<br>ម៉ោង ១៥:៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ។<br>២-សេចក្តីព្រាងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១៥/០១/១៣<br>ម៉ោង ០៩:០០ នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ។<br>២-សេចក្តីព្រាងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## ប្រចាំខែមករា ឆ្នាំ២០១៣ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១២ | ១៧/០១/១៣<br>ម៉ោង ១៥:៣០ នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ Mr. NOTABAERT និង Mr. MENANTEAU (SCA) នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៨/០១/១៣<br>ម៉ោង ០៨:៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍយុវជន និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍយុវជន។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ។<br>៣-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៣-២០១៥។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៤ | ២២/០១/១៣<br>ម៉ោង ០៨:០០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការចំណតផែកុងតឺន័រថ្មី របស់កំពង់ផែស្វយ័តភ្នំពេញ ក្រោមកម្ចីឥណទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។ |
| ១៥ | ២៣/០១/១៣<br>ម៉ោង ០៨:០០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចែកបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ក្នុងភូមិតាលាក់ខាងជើង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅភូមិតាលាក់ខាងជើង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ |
| ១៦ | ២៤/០១/១៣<br>ម៉ោង ១៥:៣០ នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៧ | ២៥/០១/១៣<br>ម៉ោង ០៩:០០ នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ញឹក គោសល្យវិទ្យា** ឯកឧត្តម **ម៉ាន់ ឈឿន** និងឯកឧត្តម **ថេង ស៊ីធឿន** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | ២៩/០១/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតវិទ្យាស្ថានវ៉ាន់ដា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលពិព័រណ៍ពាណិជ្ជកម្មកោះពេជ្រ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៣

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០១/១៣<br>ម៉ោង ១៦:០០ នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍ យុវជន និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន។<br>២-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៣-២០១៥។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ២៣/០១/១៣<br>ម៉ោង ០៨:០០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចែកបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ក្នុងភូមិតាលាក់ខាងជើង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅភូមិតាលាក់ខាងជើង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ |

## ឯកឧត្តម ឌុយ ឆៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៥/០១/១៣<br>ម៉ោង ០៩:០០ នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ។<br>២-សេចក្តីព្រាងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ២៣/០១/១៣<br>ម៉ោង ០៨:០០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចែកបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ក្នុងភូមិតាលាក់ខាងជើង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅភូមិតាលាក់ខាងជើង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៣

## ឯកឧត្តម ម៉ាន់ សិរុណា អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០១/១៣<br>ម៉ោង ១៦:០០ នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍ យុវជន និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន។<br>២-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៣-២០១៥។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៤/០១/១៣<br>ម៉ោង ០៨:៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌ឆ្មប។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៣ | ១៥/០១/១៣<br>ម៉ោង ០៩:០០ នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ។<br>២-សេចក្តីព្រាងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៨/០១/១៣<br>ម៉ោង ០៨:៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍយុវជន និង សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍយុវជន។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ។<br>៣-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៣-២០១៥។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

# សិក្ខាសាលា
## ស្តីពី
# បន្ទុកចំណាយបញ្ញត្តិកម្ម

នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ នៅសណ្ឋាគារភ្នំពេញ ឯកឧត្តម [illegible] ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) ធ្វើជាអធិបតីក្នុងអង្គសិក្ខាសាលាស្តីពីបន្ទុកចំណាយបញ្ញត្តិកម្ម ដែលរៀបចំដោយក្រុមការងារអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងធនាគារអភិវឌ្ឍន៍អាស៊ី(ADB) តាមរយៈក្រុមហ៊ុន POHL Consulting & Associates ដោយមានការអញ្ជើញចូលរួមពីខាងវិស័យឯកជន និងសមាជិក សមាជិកា ក.ស.វ. មួយចំនួន។

ក្នុងឱកាសនោះ ឯកឧត្តម [illegible] បានមានប្រសាសន៍ថា “ ខ្ញុំសូមជម្រាបថា ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី បាននឹងកំពុងអនុវត្តគម្រោងស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ហៅកាត់ថា "RIA" អស់រយៈជាងមួយឆ្នាំមកហើយ ដែលក្នុងដំណាក់កាលសាកល្បងនេះមានក្រសួងចំនួនបួនគឺក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ និងក្រសួងបរិស្ថាន ចូលរួមអនុវត្តគម្រោង។



គោលបំណងនៃRIA គឺបង្កើតបញ្ញត្តិកម្មឲ្យមានប្រសិទ្ធផល និងប្រសិទ្ធភាព ដែលនឹងរួមចំណែកក្នុងការពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ធុរកិច្ច។ ម្យ៉ាងវិញទៀតវានឹងជាផ្នែកមួយនៃរបៀបវារៈរបស់រាជរដ្ឋាភិបាលនៅក្នុងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទីពីរ ដែលផ្តោតលើអភិបាលកិច្ចល្អ កំណែទម្រង់ និងប្រសិទ្ធភាពបញ្ញត្តិកម្ម ដើម្បីសម្រេចនូវកំណើនសេដ្ឋកិច្ច បង្កើតការងារ និងការកាត់បន្ថយភាពក្រីក្រ។

សិក្ខាសាលានេះគឺជាសិក្ខាសាលាដំបូង ក្នុងចំណោមសកម្មភាពនានាដែលក្រុមគម្រោង RIA បានរៀបចំឡើងដើម្បីផ្សារភ្ជាប់ជាមួយនឹងផ្នែកឯកជន។ នៅប្រទេសផ្សេង ៗទៀត វិស័យឯកជនគឺជាអ្នកនាំមុខក្នុងការជំរុញឲ្យមានការកាត់បន្ថយបន្ទុកបញ្ញត្តិកម្ម។ ឧទាហរណ៍ក្រុមប្រឹក្សាធុរកិច្ចអូស្ត្រាលី ( Business Council of Australia ឬ BCA ) បាននឹងកំពុងទទូចឲ្យរដ្ឋាភិបាលអូស្ត្រាលី ចាត់វិធានការកាត់បន្ថយបន្ទុកបញ្ញត្តិកម្ម។ ក្រុមប្រឹក្សានេះបានស្នើជាសាធារណៈជាច្រើនជូនរដ្ឋាភិបាល ហើយបានលើកយោបល់នៅក្នុងវេទិកាមួយចំនួនដូចជានៅក្នុងសារព័ត៌មានក្នុងសិក្ខាសាលាជាដើម។ ក្រុមប្រឹក្សាធុរកិច្ចអូស្ត្រាលី និងសមាគមធុរកិច្ចដទៃទៀត បានក្លាយជាអ្នកចូលរួមដ៏សំខាន់នៅក្នុងដំណើរការកំណែទម្រង់លិខិតបទដ្ឋានគតិយុត្ត នៅក្នុងប្រទេសអូស្ត្រាលី។

នៅក្នុងកិច្ចប្រជុំកំពូលធុរកិច្ច និងវិនិយោគអាស៊ាននាពេលថ្មីនេះ ដែលប្រារព្ធធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញកាលពីថ្ងៃទី១៦-១៨ ខែវិច្ឆិកា ឆ្នាំ២០១២ គណៈប្រតិភូ និងអ្នកដឹកនាំធុរកិច្ចជាច្រើន បានបញ្ជាក់ពីភាពចាំបាច់ឲ្យមានក្របខ័ណ្ឌច្បាប់សមស្រប និងការគ្រប់គ្រងបន្ទុកចំណាយបញ្ញត្តិកម្ម។





យោងតាមរបៀបវារៈរបស់អាស៊ាន របាំងពាណិជ្ជកម្មនិងសេវាកម្មក្នុងចំណោមប្រទេសជាសមាជិក នឹងត្រូវបានកាត់បន្ថយដល់កម្រិតសូន្យ ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ ដូច្នេះការកាត់បន្ថយបន្ទុកបញ្ញត្តិកម្មគឺជាធាតុដ៏សំខាន់ក្នុងការលើកកំពស់សមត្ថភាពប្រកួតប្រជែងរបស់ធុរកិច្ចកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា ដឹងថាលិខិតបទដ្ឋានគតិយុត្ត គឺជាផ្នែកដ៏សំខាន់នៃសង្គមសម័យទំនើប។ ហើយយើងក៏ត្រូវធ្វើឲ្យប្រាកដថា លិខិតបទដ្ឋានគតិយុត្ត មិនបានដាក់ជាបន្ទុកហួសហេតុពេកមកលើធុរកិច្ច ដែលធ្វើឲ្យពាណិជ្ជកម្មមិនមានសមត្ថភាពប្រកួតប្រជែងនោះឡើយ។ ហេតុដូច្នេះសារៈសំខាន់របស់គម្រោង RIA គឺជៀសវាងការដាក់បន្ទុកបញ្ញត្តិកម្មមិនចាំបាច់ដល់ធុរកិច្ច។ ពិតប្រាកដណាស់ យើងមិនអាចសម្រេចកិច្ចការនេះបានដោយគ្មានកិច្ចសហប្រតិបត្តិការពីផ្នែកឯកជនបានឡើយ។ ដូច្នេះយើងនឹងធ្វើការពិគ្រោះយោបល់ជាមួយនឹងវិស័យឯកជន ទាំងកម្រិតបច្ចេកទេស ទាំងកម្រិតគោលនយោបាយ។

- នៅកម្រិតបច្ចេកទេស យើងនឹងធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ដើម្បីវាយតម្លៃលើផលប៉ះពាល់នៃសំណើបញ្ញត្តិកម្ម ឬនិយាយម្យ៉ាងទៀតថា ដើម្បីប៉ាន់ស្មានពីបន្ទុកចំណាយបញ្ញត្តិកម្ម។ លទ្ធផលនៃការពិគ្រោះយោបល់បែបនេះនឹងដាក់បញ្ចូលនៅក្នុងរបាយការណ៍RIA ដែលត្រូវដាក់ជូនដល់ថ្នាក់ដឹកនាំមុនពេលធ្វើការសម្រេចចិត្តលើសំណើបញ្ញត្តិកម្ម។

- នៅកម្រិតគោលនយោបាយ យើងត្រូវការយោបល់ឆ្លើយតបរបស់លោកអ្នកទាក់ទងនឹងថាតើត្រូវធ្វើឲ្យគម្រោង RIA នេះប្រសើរឡើងដោយរបៀបណា?

RIA នឹងជួយរដ្ឋាភិបាលក្នុងការបង្កើតបញ្ញត្តិកម្មឲ្យកាន់តែប្រសើរឡើងតាមរយៈការផ្តល់ការវិភាគផ្នែកសេដ្ឋកិច្ច ។ RIA ដែលនឹងត្រូវអនុវត្តនៅកម្ពុជា គឺផ្អែកលើគោលការណ៍នៃការប្រតិបត្តិបញ្ញត្តិកម្មល្អ របស់អាស៊ាន (Good Regulatory Practice ឬ GRP) ហេតុដូច្នេះ វានឹងជួយដល់ផ្នែកធុរកិច្ចឲ្យ ត្រៀមខ្លួនរួចជាស្រេចសម្រាប់អាស៊ាន នៅឆ្នាំ២០១៥។ សំខាន់ជាងនេះទៅទៀត ការអនុវត្តនីតិវិធី RIA នាំឲ្យការសម្រេចចិត្តមានតម្លាភាព និងជំរុញឲ្យអភិបាលកិច្ចបានល្អ។

ខ្ញុំសូមយកឱកាសនេះដើម្បីសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅដល់ សម្តេចអគ្គមហាសេនាបតីតេជោ ⊠⊠⊠⊠ ⊠⊠⊠ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានយល់ព្រមបង្កើតគម្រោងRIA និងខ្ញុំក៏សូមអរគុណដ៏ស្មោះស្ម័គ្រដល់ឯកឧត្តមបណ្ឌិតសភាចារ្យ ⊠⊠⊠ ⊠⊠⊠ ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានផ្តល់ការណែនាំនិងការគាំទ្រយ៉ាងពេញទំហឹងដល់គម្រោង RIA នេះ។

ខ្ញុំក៏សូមអរគុណ ធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានផ្តល់ជំនួយឥតសំណង និងការប្តេជ្ញាយ៉ាងមុតមាំក្នុងការគាំទ្រគម្រោង RIA។

ខ្ញុំដឹងថា ពេលវេលាគឺជាមាសប្រាក់សម្រាប់អ្នកធុរកិច្ច ។ ហេតុដូច្នេះ ខ្ញុំសូមអរគុណឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមសិក្ខាសាលានេះ។ ខ្ញុំសូមលើកទឹកចិត្តឯកឧត្តម លោកជំទាវ លោក លោកស្រី ឲ្យចូលរួមក្នុងសកម្មភាពនានារបស់គម្រោង RIA នៅពេលអនាគត។ ការចូលរួមជាមួយនឹងគម្រោងនេះនឹងជួយលោកអ្នក ក៏ដូចជាជួយយើងខ្ញុំ និងជួយប្រទេសកម្ពុជាដែរ។"

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅៈ | **ឯកឧត្តម គីម សយសាម៉ាឡែន** | អនុប្រធាន ក.ស.វ. |
| និពន្ធនាយកៈ | **ឯកឧត្តម ខ៉ាន់ តិរុណា** | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទៈ | **ឯកឧត្តម អេង រត្នមុនី** | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ចៈ | **ឯកឧត្តម ម៉ម សារិទ្ធ** | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយៈ | **លោក ម៉ក់ ធារ៉ា** | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួលៈ | **លោក សយ វាស្នា** | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូបៈ | **លោក មុត ភក្កដា** | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខៈ ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខៈ ០២៣ ២១១ ៩៤៣

E-mail: veasna@live.in